# សំណួរដែលបានសួរជាញឹកញាប់នៃកម្មវិធីច្រកផ្លូវស្រឡះ

***អ្វីទៅហៅថាកម្មវិធីច្រកផ្លូវស្រឡះ?***

ក្រុង Seattle គឺជាដៃគូជាមួយនឹងក្រុមហ៊ុនប្រមូលសំរាមនៅក្នុងមូលដ្ឋាន និងអតិថិជននៅ downtown ដើម្បីបន្ថយការអាចដាក់ធុងរទេះសំរាមនៅ កន្លែងអាចប្រើផ្លូវសាធារណៈ។ គោលបំណងនៃកម្មវិធីគឺដើម្បីៈ

- បង្កើតមណ្ឌលពាណិជ្ជកម្មឲ្យស្អាត, មានសុវត្ថិភាព
- បន្ថយឧប្បត្តិហេតុនៃតិរិយាបថខុសរូវជួបវេណី និងសកម្មភាពខុសច្បាប់នៅតាមច្រកផ្លូវ
- បង្កើនទំនាញអារម្មណ៏នៃច្រកផ្លូវសំរាប់អ្នកថ្មើជើងប្រើប្រាស់
- អនុញ្ញាតឲ្យមានការចេញចូលប្រសើរតាមច្រកផ្លូវសំរាប់សេវាពាណិជ្ជកម្ម ដូចជាការដឹកជញ្ជូនចែកចាយហើយនិងអាចពង្រីកសកម្មភាព ពាណិជ្ជកម្ម

***តើជនណាដែលនឹងត្រូវមានការប៉ះទង្គិច?***

ច្បាប់របស់នាយកថ្មីហាមឃាត់ពីការដាក់ធុងសំរាមជាអចិន្ត្រៃយ៏នៅតាមផ្លូវឆ្លងកាត់សាធារណៈនៅម្តុំ Downtown, Belltown និង Pioneer Square ។ សូមយោងតាមផែនទីកម្មវិធីតំបន់។ កម្មវិធីនេះមានប៉ះពាល់ដល់អ្នក បើហាងជំនួញរបស់អ្នក ឬអាគារ ជួលរបស់អ្នកស្ថិតនៅក្នុងម្តុំទាំងនេះ ហើយអ្នកដាក់ធុងសំរាម, រទេះស្បោងសំរាមប្លាស្ទិក, ឬធុងរទេះផ្សេងៗទៀតនៅតាមផ្លូវឆ្លងកាត់ សាធារណៈ ដោយគ្មានការអនុញ្ញាតឲ្យប្រើប្រាស់ផ្លូវ។ ច្បាប់សំរាប់ប្រើប្រាស់ផ្លូវ គឺជាធម្មតាបានចេញឲ្យដោយសាលាក្រុង សំរាប់ការដាក់ធុងសំរាមជាបណ្តោះអាសន្ននៅពេលសាងសង់នឹងធុងសំរាប់ដាក់របស់រុះរើចោល (C&D) ។ បើអ្នកមិនដាក់ធុង សំរាមនៅតាមផ្លូវឆ្លងកាត់ទីសាធារណៈ ឬមិនមានច្បាប់ឲ្យប្រើប្រាស់សំរាប់ដាក់ធុងសំរាមនៃ C&D របស់អ្នកទេ នៅពេលនោះ ច្បាប់នេះមិនមែនប៉ះពាល់ដល់អ្នកដោយផ្ទាល់ទេ។

***តើនៅពេលណាការនេះនឹងត្រូវផ្លាស់ប្តូរការប្រមូលសំរាម?***

ចាប់ផ្តើមពីខែមេសាឆ្នាំ 2009, ច្បាប់ចាប់ផ្តើមកំរិតចំពោះធុងសំរាមដែលដាក់នៅតាមតំបន់ពាណិជ្ជកម្មនៃ Downtown, Belltown និង Pioneer Square ។ សាលាក្រុងនឹងមានកិច្ចសន្យាការប្រមូលសំរាមថ្មីចាប់ផ្តើមនៅថ្ងៃទី 30 ខែមិនា ឆ្នាំ 2009 ដើម្បីផ្តល់ការ បំរើដល់អតិថិជនដែលមានការប៉ះពាល់ ជាមួយនឹងសេវាដទៃថ្មី ដោយឲ្យប្រើស្បោងសំរាប់ប្រមូលសំរាមរហូតដល់ទៅបីដងក្នុងមួយថ្ងៃ នៅក្នុងមូលដ្ឋានទាំងនេះ។ អតិថិជនដែលប្រើស្បោងចោលសំរាម នឹងត្រូវបានទាក់ទងដោយក្រុមអ្នកផ្តល់ការបំរើផ្នែកការប្រមូលសំរាមថ្មី ដើម្បីផ្តល់ដំណឹងពីជំរើសនៃសេវាកម្មរបស់ពួកគេ ហើយនិងផែនការផ្លាស់ប្តូរនៅក្នុងខែកុម្ភៈ ឆ្នាំ 2009 ។

***តើមានមធ្យោបាយអ្វីឲ្យរួចផុតពីការតំរូវថ្មីដែរឬទេ?***

គឺនឹង***គ្មានការលើកលែងត្រូវបានផ្តល់ឲ្យសំរាប់ដាក់ធុងសំរាមនៅតាមផ្លូវឆ្លងកាត់សាធារណៈ*** នៅតាមតំបន់ពាណិជ្ជកម្មទេ។ ទោះបីយ៉ាង ណាក៏ដោយ ការប្រមូលសំរាមសំរាប់ប្រេងដាំស្លដែលជួបតាមការតំរូវនៃច្បាប់សាធារណៈនិងបរិស្ថានគឺត្រូវលើកលែងជាលក្ខណៈពិសេស។ ការលើកលែងក៏អាចត្រូវបានផ្តល់ឲ្យដោយក្រសួង SPU សំរាប់ធុងរទេះដែលចោលសម្ភារៈដូចតទៅនេះ:

1) រទេះដែលមានបិទស្លាក (32, 60 ឬ 90 ក្លាឡុង) ដែលមានបិទគំរបជិតត្រឹមត្រូវសំរាប់ដាក់ដាច់ឡែកនៃសំណល់កាកអាហារ/ ក្រដាសខ្ចប់អាហារ នឹងសំណស់កាត់តំរឹមស្មួនច្បារ បើសិនជាគ្មានកន្លែងដាក់ធុងនៅក្នុងបរិវេណឯកជន ដែលបានត្រួតពិនិត្យ ដោយសាលាក្រុងនោះទេ។.
2) រទេះដែលមានបិទស្លាក (32, 60 ឬ 90 ក្លាឡុង) សំរាប់ដាក់ចោលកញ្ចក់ បើសិនជាគ្មានកន្លែងដាក់ធុងនៅក្នុងបរិវេណឯកជន ដែលបានត្រួតពិនិត្យដោយសាលាក្រុងនោះទេ។
3) រទេះដែលមានបិទស្លាក (32, 60 ឬ 90 ក្លាឡុង) សំរាប់ដាក់ចោលលាមកសត្វ បើសិនជាគ្មានកន្លែងដាក់ធុងនៅក្នុងបរិវេណ ឯកជន ដែលបានត្រួតពិនិត្យដោយសាលាក្រុងនោះទេ។.

គ្រប់អតិថិជនដែលចង់មានការលើកលែងសំរាប់ដាក់រទេះសំរាមនៃសំណល់សំរាប់ប្រើធ្វើជីរ, កញ្ចក់ និងលាមកសត្វ ហើយនិងចង់ បានប្រើប្រាស់រយៈពេលយូរនៅតាមច្រកផ្លូវសាធារណៈ ត្រូវតែទាក់ទងទៅក្រសួងទឹកភ្លើងសាធារណៈនៃក្រុង Seattle ។ ការខ្វះ ខាតនៃកន្លែងដាក់រទេះធុងសំរាមនៅតាមដីឯកជននឹងត្រូវការឲ្យមានការពិនិត្យផ្ទៀងផ្ទាត់។ អាយុកាលនៃអាគារនឹងត្រូវជាកត្តាមួយ ថាតើក្រសួង SPU នឹងត្រូវឬមិនត្រូវផ្តល់ការលើកលែងឲ្យឬទេ ដោយសារតែគ្រប់អាគារដែលបានសាងសង់ឬកំពុងទទួលការសង់កែ ប្រែយ៉ាងច្រើននៅក្រោយឆ្នាំ 2000 ត្រូវតំរូវឲ្យមានកន្លែងសំរាប់ចោលរបស់សំរាប់ប្រើប្រាស់ឡើងវិញនិងធុងសំរាម។

***តើជនណាដែលខ្ញុំត្រូវទាក់ទងសំរាប់ទទួលការលើកលែង?***

សូមទាក់ទងទៅ Tom Gannon នៃក្រសួងទឹកភ្លើងក្រុង Seattle តាមលេខ (206) 684-3453 ឬតាមរយៈអ៊ីមែល SPUClearAlleys@Seattle.Gov ។

***តើស្បោងសំរាមនឹងមានទំហំប៉ុន្មានសំរាប់ស្បោងបង់ឈ្នួលមុន ហើយនិងឈ្នួលស្បោងថ្លៃប៉ុន្មានសំរាប់ការប្រមូល?***

ស្បោងសំរាមនឹងមានទំហំពីរយ៉ាង: ស្បោងទំហំ 33 ក្លាឡុង (33" ទៅ 39") នឹងទារឈ្នួល $5.00; និងស្បោងទំហំ 15 ក្លាឡុង (24" ទៅ 32") នឹងទារឈ្នួល $3.50 ។

***តើកំរិតទម្ងន់ប៉ុន្មានសំរាប់ស្បោងបង់ឈ្នួលមុន?***

ទម្ងន់កំរិតសំរាប់ស្បោង 33-ក្លាឡុង គឺ 40 ផោន និងទម្ងន់កំរិតសំរាប់ស្បោង 15-ក្លាឡុងគឺ 20 ផោន។

***តើស្បោងដែលបង់ឈ្នួលមុននឹងត្រូវបញ្ជាទិញរបៀបណា?***

អ្នកនឹងត្រូវទាក់ទងក្រុមហ៊ុនប្រមូលសំរាមថ្មីរបស់អ្នកសំរាប់បញ្ជាទទួលស្បោងនិងផ្ញើឲ្យដោយផ្ទាល់។ បើក្រុមហ៊ុនប្រមូលសំរាមថ្មីរបស់អ្នកគឺ Cleanscapes, អ្នកអាចទាក់ទងពួកគេតាមលេខ (206) 250-7500 ឬទៅមើលវ៉ិបសៃ cleanscapes.com។ អតិថិជនផ្នែកការចាត់ចែងចោលសំរាម អ្នកអាចទៅមើលវ៉ិបសៃ www.wmnorthwest.com/seattlecap ឬទូរស័ព្ទលេខ (800) 592-9995 លេខបន្ត 777 ។

***តើកម្មវិធីច្រកផ្លូវស្រឡះនឹងត្រូវទារថ្លៃប៉ុន្មានពីខ្ញុំ?***

តារាងនេះបង្ហាញពីតំលៃសេវាប្រចាំខែសំរាប់គណនីដែលប្រើស្បោងធំសំរាប់ពាណិជ្ជកម្មជាមួយនឹងការប្រមូលសំរាមមួយដងក្នុងមួយអាទិត្យ។ តារាង បង្ហាញពីអត្រាតំលៃសំរាមពេលបច្ចុប្បន្ន និងអត្រាតំលៃធុងរទេះសំរាមថ្មី ដែលនឹងត្រូវមានសុពលភាពនៅថ្ងៃទី 30 ខែមិនា ឆ្នាំ 2009 ។ តារាងប្រើ សំរាប់ការប្តូរស្បោងសំរាមចំណុះពេញ 33 ក្លាឡុង ប្រហែលជា 6 ដែលស្មើនឹងមួយយ៉ាតគីប, សន្មត់ថារក្សាធ្វើឲ្យមានការបន្ថយសំរាមចំនួន 10% ហើយនិងរួមបញ្ចូលតំលៃសេវាគណនី។

**ឈ្នួលប្រចាំខែ**

| | ទូររទេះសំរាម 1/1/09-3/29/09 | ទូររទេះសំរាម 3/30/09-12/31/09 | ជំរើសស្បោងដែលបង់ឈ្នួលមុន |
|---|---|---|---|
| 1 យ៉ាតគីប | $ 117.72 | $ 149.00 | $ 131.66 |
| 3 យ៉ាតគីប | $ 267.97 | $ 332.15 | $ 365.48 |
| 6 យ៉ាតគីប | $ 464.72 | $ 606.90 | $ 716.21 |

អត្រាឈ្នួលសំរាប់អាគារពលរដ្ឋមានគ្រួសារច្រើន បង្ហាញឲ្យឃើញប្រហាក់ប្រហែលគ្នា ប៉ុន្តែទម្រង់តំលៃមិនស្មើគ្នាដូចដែលបានបង្ហាញនៅខាងលើ សំរាប់អតិថិជនផ្នែកពាណិជ្ជកម្មដែលចោលសំរាមនោះទេ។ ថែមពីលើនោះ សេវាសំរាប់ស្បោងដែលបង់ឈ្នួលមុនគឺជាប្រព័ន្ធ "បង់ឈ្នួលតែសំរាប់ សំរាមអ្នកចោល" ដូច្នេះគេមិនទារឈ្នួលសំរាប់ចន្លោះទូររទេះសំរាមដែលទំនេរមិនប្រើទេ បើអ្នកប្រើក្រុមហ៊ុនសំរាមនេះ។ ប្រព័ន្ធស្បោងសំរាមដែលបង់ឈ្នួលមុននឹងអនុញ្ញាតឲ្យអ្នករករបៀបចោលសំរាមដែលអាចធ្វើបានផ្សេងទៀត និងការអាចធ្វើបាននូវការបន្ថយវិក័យប័ត្ររបស់អ្នកនៅពេល ខាងមុខ។

***តើធ្វើយ៉ាងណា បើសំរាមរបស់អ្នកមិនអាចដាក់ចូលក្នុងស្បោងបង់ឈ្នួលមុន?***

ពួកប្រមូលសំរាមនឹងអាចមានសំរាប់របស់របរដែលមានទម្ងន់តិចជាង 60 ផោន ដែលមិនអាចដាក់ចូលក្នុងស្បោងបាន។ សំរាប់របស់ធំៗ អ្នកអាចស្នើឲ្យប្រមូលជាពិសេស។ សូមទាក់ទងទៅក្រុមហ៊ុនប្រមូលសំរាមថ្មីរបស់អ្នក។

***តើក្រុមហ៊ុនប្រមូលសំរាមថ្មីរបស់ខ្ញុំនឹងត្រូវជាអ្នកប្រមូលសំណល់ផលិតឡើងវិញឬសំណល់អាហារជាមួយគ្នាដែរឬទេ?***

ហាងពណិជ្ជកម្មអាចប្រើប្រាស់ក្រុមហ៊ុនប្រមូលសំរាមដែលពួកគេជ្រើសរើសណាក៏បាន ប៉ុន្តែគ្មានធុងសំរាមនៃក្រុមហ៊ុនណាឲ្យដាក់នៅតាមច្រកឆ្លងកាត់សាធារណៈទេ លើកលែងតែមានការអនុញ្ញាតឲ្យអតិថិជនដាក់ធុងសំណល់អាហារ, កញ្ចក់, នឹងលាមកសត្វ នៅក្រោយពេលដែលបានត្រួតពិនិត្យដោយសាលាក្រុង ដែលគ្មានកន្លែងដាក់ធុងនៅក្នុងបរិវេណឯកជន។

***តើខ្ញុំអាចទទួលឱកាសនៅទីណា ពីរបៀបសន្សំប្រាក់លើផ្នែកវិក័យប័ត្រចោលសំរាមនិងរបៀបចាត់ចែងសំរាមរបស់ខ្ញុំ?***
សំរាប់ព័ត៌មានពីរបៀបសន្សំប្រាក់ ដោយការបន្ថយសំរាមនិងរបស់របរសំរាប់ប្រើឡើងវិញឲ្យច្រើន ចូរទាក់ទងទៅ Resource Venture។ ចូរទៅមើលវិបសៃរបស់ពួកគេនៅ **resourceventure.org** ឬទាក់ទងពួកគេតាមលេខ (206) 343- 8505 ឬអ៊ីមែល help@resourceventure.org ។

***សូមកត់សំគាល់ថា គ្មានការផ្លាស់ប្តូរអ្វីមួយទេរហូតដាល់ថ្ងៃទី 30 ខែមិនា ឆ្នាំ 2009 ហើយនឹងមិនមានការប៉ះពាល់ដល់អ្នកទេ បើអ្នកដាក់ធុងសំរាមរបស់អ្នកនៅកន្លែងដើឯកជន។***